# កម្មវិធី

## ពិធីបើកវេទិការដ្ឋាភិបាលឌីជីថល និងពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត

ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤

| | |
|---|---|
| ០៦:០០ នាទីព្រឹក | ជួបជុំមន្ត្រីរាជការ និងសមាជិក សមាជិកា នៃអង្គពិធី |
| ០៧:០០ នាទីព្រឹក | ការអញ្ជើញមកដល់ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ |
| ០៧:៣០ នាទីព្រឹក | **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត** អញ្ជើញដល់ |

## ចាប់ផ្តើមកម្មវិធី

០៧:៣៥ នាទីព្រឹក

១.ការទស្សនាពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យារដ្ឋាភិបាលឌីជីថលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត**

២.គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា

៣.សុន្ទរកថាស្វាគមន៍ និងរបាយការណ៍របស់ **ឯកឧត្តមរដ្ឋមន្ត្រី ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

៤.សុន្ទរកថារបស់ **ឯកឧត្តមបណ្ឌិត កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន

៥.សុន្ទរកថាគន្លឹះ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

៦.ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ចំនួន ៤ រួមមាន៖

- ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងបច្ចេកវិទ្យានិងទូរគមនាគមន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជានិងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំកម្ពុជា
- ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនិងសន្តិសុខនៃសាធារណរដ្ឋកូរ៉េ
- ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារជាតិសង្គមព័ត៌មាននៃសាធារណរដ្ឋកូរ៉េ

***<u>ចំណាំ៖</u>*** *កម្មវិធីអាចមានការកែប្រែក្នុងករណីចាំបាច់។*



# របៀបវារៈ

## វេទិការដ្ឋាភិបាលឌីជីថល

ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១១-១២ ខែមីនា ឆ្នាំ២០២៤

| ម៉ោង | **ថ្ងៃទី១** (ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤) |
|---|---|
| ១២:៣០ | ជួបជុំអ្នកចូលរួមក្នុងវេទិកា |
| ១២:៤៥ | គណៈអធិបតីអញ្ជើញដល់ |
| ១៣:០០ - ១៣:១៥ | **កម្មវិធីសម្ពោធជាផ្លូវការ «មជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថល កម្ពុជា-កូរ៉េ»** ក្រោមអធិបតីភាព **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង**លោកបណ្ឌិត Jong-Sung Hwang** នាយកទីភ្នាក់ងារសង្គមព័ត៌មានជាតិកូរ៉េ (NIA) |
| ១៣:១៥ - ១៥:០០ | **កិច្ចពិភាក្សាកម្រិតខ្ពស់ថ្នាក់រដ្ឋមន្ត្រី៖** "ការចែករំលែកចំណេះដឹងក្នុងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល៖ គោលនយោបាយនិងការអនុវត្ត"<br><br>**ខ្លឹមសារសង្ខេប៖**<br>កិច្ចពិភាក្សាកម្រិតខ្ពស់ថ្នាក់រដ្ឋមន្ត្រី នឹងផ្តល់ជាឱកាសសំខាន់ដើម្បីពិភាក្សាអំពីស្ថានភាព បញ្ហាប្រឈម និងដំណើរឆ្ពោះទៅរកបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងពង្រឹងកិច្ចសហ-ប្រតិបត្តិការឌីជីថលក្នុងតំបន់ជាមួយរដ្ឋមន្ត្រីឌីជីថលអាស៊ាន ឆ្ពោះទៅរកការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលប្រកបដោយបរិយាបន្ន។<br><br>**សម្របសម្រួលដោយ៖ លោក Jo Scheuer** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា<br><br>**វាគ្មិន៖**<br>• ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា<br>• ឯកឧត្តម Boviengkham VONGDARA រដ្ឋមន្ត្រីក្រសួងបច្ចេកវិទ្យានិងគមនាគមន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ<br>• ឯកឧត្តម Gobind Singh Deo រដ្ឋមន្ត្រីឌីជីថល នៃប្រទេសម៉ាឡេស៊ី<br>• លោកជំទាវ Jocelle Batapa-Sigue អនុរដ្ឋមន្ត្រីក្រសួងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃសាធារណៈរដ្ឋហ្វីលីពីន<br>• ឯកឧត្តម Phan Tam អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាននិងគមនាគមន៍ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម |
| ១៥:០០ – ១៥:៣០ | សម្រាកពិសារអាហារសម្រន់ |

| | |
|---|---|
| ១៥:៣០ – ១៦:៣០ | **ប្រធានបទទី១ ៖ទិដ្ឋភាពទូទៅនៃគោលនយោបាយពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថលនៅកម្ពុជា**<br><br>**ខ្លឹមសារសង្ខេប៖**<br>ការបង្ហាញពីទិដ្ឋភាពទូទៅនៃការធ្វើបរិវត្តកម្មឌីជីថលកម្ពុជា រួមមានក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។<br><br>**សម្របសម្រួលដោយ៖ លោកស្រី** Alissar Chaker តំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា<br><br>**វាគ្មិន៖**<br>• ដំណើរឆ្ពោះទៅកេសង្គមឌីជីថលកម្ពុជា ដោយ **ឯកឧត្តម សុខ ពុទ្ធិវុធ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល<br>• គំនិតផ្តួចផ្តើមសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលដោយ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល<br>• គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ដោយ **ឯកឧត្តម ជា សេរីវឌ្ឍ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។ |
| ១៦:៣០ – ១៨:០០ | **ប្រធានបទទី២៖ ឃ្នាស់បច្ចេកវិទ្យាក្នុងការជំរុញល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល (ថ្នាលនិងសេវារដ្ឋាភិបាលឌីជីថល)**<br><br>**ខ្លឹមសារសង្ខេប៖**<br>ការស្វែងយល់ពីតួនាទី នៃបច្ចេកវិទ្យាក្នុងការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងរដ្ឋាភិបាលក្រោមទិដ្ឋភាពផ្សេងៗនៃការធ្វើបរិវត្តកម្មចាប់ពីការយល់ដឹងអំពីគោលគំនិតនៃរដ្ឋាភិបាលឌីជីថល រហូតដល់ការប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗ ដែលអាចជួយសម្រួលដល់ការធ្វើបរិវត្តកម្ម។<br><br>**បទបង្ហាញ៖**<br>• ឧត្តមានុវត្តន៍នៃឃ្នាស់បច្ចេកវិទ្យាលើបរិវត្តកម្មរដ្ឋាភិបាលឌីជីថលនៅប្រទេសសិង្ហបុរីដោយ **លោកស្រី** Sarah Espaldon ប្រធានក្រុមថ្នាលរដ្ឋាភិបាលបើកចំហ នៃទីភ្នាក់ងារ GovTech ប្រទេសសិង្ហបុរី<br>• ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល ដោយ **លោក** Calum Handforth ប្រធានគ្រប់គ្រងយុទ្ធសាស្ត្រកម្មវិធីឌីជីថល ប្រធានការិយាល័យឌីជីថលនៃ UNDP<br>• គំនិតផ្តួចផ្តើមរបស់ប្រទេសជប៉ុនដើម្បីសម្រេចបានបរិវត្តកម្មរដ្ឋាភិបាលឌីជីថល ដោយ **ឯកឧត្តម** NOMURA Eigo អគ្គនាយកទទួលបន្ទុកកិច្ចការអន្តរជាតិអគ្គនាយកដ្ឋាន យុទ្ធសាស្ត្រសកល នៃក្រសួងមហាផ្ទៃនិងគមនាគមន៍នៃប្រទេសជប៉ុន |

| | |
|---|---|
| | **សម្របសម្រួលដោយ៖ ឯកឧត្តម ឆែម សិរីវត្តិវីលៀម** ទីប្រឹក្សាយុទ្ធសាស្ត្រនៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី<br><br>**វាគ្មិន៖**<br>• ថ្នាល verify.gov.kh ដោយ **ឯកឧត្តម ជាង វុត្ថា** ទីប្រឹក្សាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ថ្នាល go.gov.kh ដោយ **លោក តាំង ប៊ុនហុង** ប្រធាននាយកដ្ឋានគោលនយោបាយនិងនីតិកម្ម នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>• ថ្នាល form.gov.kh ដោយ **លោក អ៊ិន សុវណ្ណ** ប្រធាននាយកដ្ឋានបរិវត្តកម្មរដ្ឋាភិបាលឌីជីថល នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>• Sarika Telegram Bot ដោយ **លោក ស្រ៊ី ជ្រា** អ្នកគ្រប់គ្រងគម្រោងបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>• ថ្នាល nomsa.gov.kh ដោយ **លោក ឌីបូ បញ្ញា** អ្នកគ្រប់គ្រងការដាក់ដំណើរការថ្នាល នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
| **ម៉ោង** | **ថ្ងៃទី២** (ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤) |
| ០៨:០០ | ជួបជុំអ្នកចូលរួមក្នុងវេទិកា |
| ០៨:៣០ - ០៩:៣០ | **ប្រធានបទទី៣៖ ការសម្របខ្លួនដើម្បីអនុវត្តគោលនយោបាយ ការពិនិត្យមើលភាពខុសគ្នារវាងការរៀបចំផែនការនិងការអនុវត្តជាក់ស្តែងក្នុងការធ្វើបរិវត្តកម្មឌីជីថល**<br><br>**ខ្លឹមសារសង្ខេប៖**<br>ការស្វែងយល់ពីដំណើរការនៃការសម្របខ្លួនទៅនឹងការអនុវត្តគោលនយោបាយ ភាពខុសគ្នារវាងគំនិតផ្តួចផ្តើមរៀបចំផែនការ និងការអនុវត្តជាក់ស្តែងក្នុងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងប្រសិទ្ធិភាពរបស់ស្ថាប័ននានាក្នុងមាគ៌ាធ្វើបរិវត្តកម្ម រួមមាន ការសម្របសម្រួល ការគ្រប់គ្រងការផ្លាស់ប្តូរ បច្ចេកវិទ្យា និងនិរន្តរភាព។<br><br>**បទបង្ហាញ៖** បញ្ហាប្រឈមក្នុងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថលនៅកម្ពុជា ដោយ **លោក តាំង ប៊ុនហុង** ប្រធាននាយកដ្ឋានគោលនយោបាយនិងនីតិកម្ម នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br><br>**សម្របសម្រួលដោយ៖ លោក Ashish Narayan** អ្នកសម្របសម្រួលកម្មវិធី នៃការិយាល័យ ITU ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក<br><br>**វាគ្មិន ៖**<br>• **លោកបណ្ឌិត Ooh Koon Tian** អ្នកពិគ្រោះយោបល់ជាន់ខ្ពស់ នៃបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋាភិបាល នៃទីភ្នាក់ងារ GovTech ប្រទេសសិង្ហបុរី |



| | | |
|---|---|---|
| | • **លោក Youngjun Song** អនុប្រធាន KOICA ប្រចាំនៅកម្ពុជា<br>• **លោក Foong Chee Kheong** មន្ត្រីទទួលបន្ទុកផ្នែកច្បាប់ នៃ Axiata គ្រុប<br>• **លោក តាំង ប៊ុនហុង** ប្រធាននាយកដ្ឋានគោលនយោបាយនិងនីតិកម្ម នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | |
| ០៩:៣០ - ០៩:៤៥ | • ការប្រកាសសូចនាករគន្លឹះសម្រាប់រដ្ឋាភិបាលឌីជីថល<br>• ការប្រគល់-ទទួលរបាយការណ៍ពាក់ព័ន្ធនឹងបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និង របាយការណ៍ផ្សេងៗ | |
| ០៩:៤៥ – ១០:០០ | សម្រាកពិសារអាហារសម្រន់ និងទំនាក់ទំនងធុរកិច្ច | បទបង្ហាញស្តីពីមាគ៌ាទៅកាន់ការវិភាគទិន្នន័យ, AI, ឃ្លាំងទិន្នន័យ និង Blockchain ដោយ KBSL |
| ១០:០០ – ១១:១៥ | **ប្រធានបទទី៤៖ ការកសាងមូលដ្ឋាន និងទំនុកចិត្តរដ្ឋាភិបាលឌីជីថល**<br>**ខ្លឹមសារសង្ខេប៖**<br>ប្រធានបទនេះនឹងផ្តល់នូវទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលកម្ពុជា និងចែករំលែកការអនុវត្តអន្តរជាតិលើក្របខណ្ឌបច្ចេកទេសសម្រាប់ការអនុវត្តអភិក្រមរដ្ឋាភិបាលឯកភាព (Whole-of-government Approach) ផ្តល់នូវការអនុវត្តអន្តរជាតិលើការកសាងប្រព័ន្ធឌីជីថលប្រកបដោយសុវត្ថិភាពនិងបរិយាបន្ន និងការលើកកម្ពស់អន្តរប្រតិបត្តិការ។<br><br>**បទបង្ហាញ៖** សន្តិសុខសាយប័រ ដើរតួនាទីសំខាន់សម្រាប់រដ្ឋាភិបាលឌីជីថល ដោយ **លោក Reuben Karuna-Nidhi** នាយកម្មវិធីព័ត៌មានវិទ្យា និងប្រធានសន្តិសុខព័ត៌មាន (CISO) និងជាអ្នកពិគ្រោះយោបល់ផ្នែកព័ត៌មានវិទ្យា<br>**សម្របសម្រួលដោយ៖ លោក ផន ដារ៉ូ** មន្ត្រីនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br><br>**វាគ្មិន៖**<br>• ដំណើរនៃការកសាងមូលដ្ឋានគ្រឹះនិងទំនុកចិត្តរបស់រដ្ឋាភិបាលឌីជីថលកូរ៉េ ដោយ **លោកបណ្ឌិត Jong-Sung Hwang** នាយក NIA<br>• វិស្វកម្មច្បាប់សម្រាប់រដ្ឋាភិបាលឌីជីថលកម្ពុជា សន្តិសុខសាយប័រ និងកិច្ចការពារទិន្នន័យបុគ្គល ដោយ **ឯកឧត្តម គង់ ផល្លៈ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល ដោយ **ឯកឧត្តម សំ សិទ្ធិសេរី** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT)<br>• អភិក្រមរដ្ឋាភិបាលឯកភាព ដោយ **លោក Nabhonil Roy Chowdhury**, អ្នកឯកទេសរដ្ឋាភិបាលឌីជីថលប្រចាំតំបន់, GovStack, ITU<br>• ការកសាងទំនុកចិត្ត ដោយ **លោក Julian Lau** ប្រធានផ្នែកលក់សម្រាប់ទីផ្សារកំពុងរីកចម្រើន នៃ Amazon Web Service<br>• គោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា ដោយ **លោកស្រី តាន់ សូដានី** ប្រធាននាយកដ្ឋាន | |



<table>
<tr><td></td><td colspan="2">គោលនយោបាយនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍</td></tr>
<tr><td>១១:១៥ - ១២:១៥</td><td colspan="2">ប្រធានបទទី៥៖ ការចាប់យកសេវាសាធារណៈឌីជីថល<br><br>ខ្លឹមសារសង្ខេប៖<br>ប្រធានបទនេះនឹងពិភាក្សាអំពីរបៀបធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព លទ្ធភាពទទួលបាន និងបទពិសោធអ្នកប្រើប្រាស់ ការធ្វើឱ្យសេវាសាធារណៈកាន់តែមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងសេវាកម្មសាធារណៈ ចាប់តាំងពីការចុះបញ្ជីអត្តសញ្ញាណកម្ម រហូតដល់ប្រព័ន្ធបំពេញការបង់ពន្ធអនឡាញ។<br><br>សម្របសម្រួលដោយ៖ លោក Jonas Herzing ទីប្រឹក្សាជាន់ខ្ពស់ នៃមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថល នៃអង្គការ GIZ<br><br>វាគ្មិន៖<ul><li>ការចុះបញ្ជីអត្តសញ្ញាណកម្ម ដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុកចាយ បញ្ញ៉ា ទីប្រឹក្សាអមក្រសួងផែនការ និងជាអគ្គនាយករងអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ</li><li>ការគ្រប់គ្រងដែនដីឌីជីថល ដោយ ឯកឧត្តម គិត ចន្ទត្រីស្នា អនុរដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់</li><li>ការចុះបញ្ជីយានយន្តអនឡាញ ដោយ ឯកឧត្តម ហ៊ាង សុទ្ធាយុត្តិ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យានិងទំនាក់ទំនងសាធារណៈ នៃក្រសួងសាធារណការ និងដឹកជញ្ជូន</li><li>KHQR ដោយ លោក អ៊ុក សារ៉ាត អគ្គនាយករងនៃអគ្គនាយកដ្ឋានប្រតិបត្តិការ និងជាប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ នៃធនាគារជាតិនៃកម្ពុជា</li><li>គំនិតផ្តួចផ្តើមឌីជីថល X ដោយ លោក Mike Rios អ្នកឯកទេសនវានុវត្តន៍ឌីជីថល និងមាត្រដ្ឋាន ក្រុមហ៊ុន CDO</li><li>ការបង់ពន្ធតាមអនឡាញ ដោយ ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ</li></ul></td></tr>
<tr><td>១២:១៥ - ១៣:៣០</td><td>សម្រាកពិសារអាហារថ្ងៃត្រង់ និងទំនាក់ទំនងធុរកិច្ច</td><td><ul><li>បទបង្ហាញស្តីពី Smart Village, Smart Island និង GovStack ដោយ ITU</li><li>បទបង្ហាញស្តីពីធាតុសំខាន់ៗក្នុងបរិវត្តកម្មឌីជីថលវិស័យសាធារណៈ ដោយលោក TAN GIM LIM អ្នកជំនាញឧស្សាហកម្ម នៃក្រុមហ៊ុន Huawei តំបន់អាស៊ីប៉ាស៊ីហ្វិក</li></ul></td></tr>
<tr><td>១៣:៣០ - ១៤:៣០</td><td colspan="2">ប្រធានបទទី៦៖ ការជំរុញការធ្វើបរិវត្តកម្មឌីជីថលប្រកបដោយបរិយាបន្ន<br><br>ខ្លឹមសារសង្ខេប៖<br>ប្រធានបទនេះនឹងផ្តោតលើការទទួលយកអត្ថប្រយោជន៍នៃការធ្វើបរិវត្តកម្មឌីជីថលដល់សហគមន៍ ជនបទ និងដាច់ស្រយាលដែលមិនទុកនរណាម្នាក់ចោលឡើយ។ ជាពិសេស ប្រធានបទ</td></tr>
</table>



| | |
|---|---|
| | នេះនឹងពិភាក្សាអំពីចំណុចសំខាន់ៗមួយចំនួន រួមមាន ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដល់ទីជនបទដាច់ស្រយាល បរិយាបន្នឌីជីថល និងជំនាញឌីជីថល។<br><br>**សម្របសម្រួលដោយ៖ លោក ភាព ប៊ុនឡេង** មន្ត្រីកម្មវិធីជាតិ នៃ UNESCO ប្រចាំកម្ពុជា<br>**វាគ្មិន៖**<br>• ការលើកកម្ពស់ការយល់ដឹងអំពីឌីជីថល និងការចាប់យកបច្ចេកវិទ្យា ដោយ **ឯកឧត្តម ស៊ុន វាពីដ** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានដោយ **ឯកឧត្តម នាង ម៉ៅ** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• សហគមន៍ឌីជីថលកម្ពុជា និងប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ ដោយ **ឯកឧត្តម ទូច យ៉ាវ៉ាន់ឌី** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា ២០២៤-២០៣៥ ដោយ **លោក ចាន់ទី ពិសាល** ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយឌីជីថលនៃបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា |
| ១៥:០០ - ១៥:១៥ | ការសម្រាកពិសារអាហារសម្រន់ |
| ១៥:១៥ - ១៦:៤៥ | **ប្រធានបទទី៧៖ ការកើនឡើងនៃគុណតម្លៃ និងកាលានុវត្តភាពនៃមាតិកាដើមលើថ្នាលប្រព័ន្ធផ្សព្វផ្សាយ**<br><br>**ខ្លឹមសារសង្ខេប៖**<br>ប្រធានបទនេះនឹងស្វែងយល់ពីកំណើនតម្លៃ និងឱកាសនៃខ្លឹមសារដើមនៅលើថ្នាលប្រព័ន្ធផ្សព្វផ្សាយ ជាមួយនឹងការពិភាក្សានៅក្នុងទិដ្ឋភាពផ្សេងៗនៃការបង្កើតខ្លឹមសារ ក្រមសីលធម៌ ទំនួលខុសត្រូវសង្គម និងការរកប្រាក់។<br><br>**សម្របសម្រួលដោយ៖ លោកស្រី ឡាយ ស៊ីវហួង** ទីប្រឹក្សាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br><br>**វាគ្មិន៖**<br>• **លោក ប៉ុក បូរក្ស** ប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>• ការប្រើប្រាស់ថ្នាល Tiktok ដោយ **លោកស្រី ស៊ូ វ៉ូហ្សានិច** ប្រធានផ្នែកដៃគូ ក្រុមហ៊ុន httpool<br>• ការប្រើប្រាស់ថ្នាល Youtube ដោយ **លោក Danny Ardianto** ប្រធានផ្នែកទំនាក់ទំនងរដ្ឋាភិបាលនិងគោលនយោយបាយសាធារណៈ ប្រចាំតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង<br>• ខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយ **លោកស្រី នាង ស៊ុវ៉ាតនា (Dj NaNa)**<br>• កម្មវិធីរៀនចត ដោយ **លោក ឆេង សុភ័ក្រ** អ្នកផលិតខ្លឹមសារ និងរៀបចំផតខាស់<br>• ការផលិតមាតិកាអប់រំ ដោយ **លោកស្រី ចេង ស្រីតំ** នាយិកានៃស្ថាប័នផ្សព្វផ្សាយអប់រំកម្ពុជា |



| | |
|---|---|
| ១៦:៤៥ - ១៧:០០ | **១.**សុន្ទរកថាបិទដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>២.ការប្រគល់វិញ្ញាបនបត្រថ្លែងអំណរគុណ |

***<u>ចំណាំ៖</u>*** *កម្មវិធីអាចមានការកែប្រែក្នុងករណីចាំបាច់។*

